ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែកុម្ភៈ ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកុម្ភៈនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦៣០ ៨៨៣ហ.ត ស្មើនឹង១៣៧,៣៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិកររងផលប៉ះពាល់។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកុម្ភៈនេះ គឺបានរៀបចំកិច្ចប្រជុំការងារចំបាច់ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០២១នេះ មានដូចតទៅៈ

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៣០ ៩៦៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២៥៧ហ.ត ស្មើនឹង០,៦៧% និងដោយគ្រឿងយន្តចំនួន ៦២៦ ៧០៧ហ.ត ស្មើនឹង៩៩,៣៣%
- ផ្ទៃដីសាបសម្រេចបានចំនួន ២៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៣០ ៨៨៣ហ.ត ស្មើនឹង១៣៧,៣៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត លើសឆ្នាំមុន ៣៣ ៣៧៥ហ.ត។

#### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំង

-ការប្រមូលផលស្រូវប្រាំងបានចំនួន ២៤៧ ០៨៩ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ១ ០៩០ ៣៣៤តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៤១៣តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៦ ៣១៥ហ.ត ស្មើនឹង៩៧,៣៣% នៃផែនការចំនួន ៣៧ ៣១២ហ.ត តិចជាងឆ្នាំមុន ១ ៣១១ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨០ ៨៦៧ហ.ត ស្មើនឹង៩៥,៤០% នៃផែនការចំនួន ៨៤ ៧៧០ហ.ត លើសឆ្នាំមុន ១ ៥៩៣ហ.ត។

#### ១.៤ ការនាំចេញផលិតផលកសិកម្ម

១.៤.១ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៤១ ៩៤៩តោន មានការថយចុះចំនួន ៤៤ ១០០តោន (-៥១,២៥%) តិចជាងបរិមាណនាំចេញក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន ៨៦ ០៤៩តោន។ សរុបរយៈពេល២ខែនាំចេញអង្ករបានចំនួន

៧៦ ២២២តោន និងនាំចេញទៅកាន់ទិសដៅចំនួន ៣៥ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ មានចំនួន ៣៧ ៦៣០តោន ប្រទេសបារាំងឈរលំដាប់ទី២ មានចំនួន ៨ ៨៥០តោន ប្រទេសហុងកុងឈរលំដាប់ទី៣ មានចំនួន ៥ ៩៤៦តោន ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ មានចំនួន ៥ ៩២០តោន ប្រទេសអូស្ត្រាលីឈរលំដាប់ទី៥ មានចំនួន ២ ២០៦តោន ប្រទេសណូវែលហ្សេឡង់ឈរលំដាប់ទី៦ មានចំនួន ២ ១១៥តោន សាធារណរដ្ឋឆែកឈរលំដាប់ទី៧ មានចំនួន ១ ៥៨៥តោន ប្រទេសអេស្ប៉ាញឈរលំដាប់ទី៨ មានចំនួន ១ ៣៩៧តោន ប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី៩ មានចំនួន ១ ២០៨តោន និងចក្រភពអង់គ្លេសឈរលំដាប់ទី១០ មានចំនួន ៩៨៥តោន ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៨៤ក្រុមហ៊ុន។

**១.៤.២ ការនាំចេញកសិផលផ្សេងៗ**

បរិមាណនាំចេញផ្លែចេកស្រស់ចំនួន ៤២ ១៥៦តោន ទៅកាន់ប្រទេសចិន ជប៉ុន សិង្ហបុរី និងប្រទេសវៀតណាម។ ផ្លែស្វាយស្រស់ចំនួន ២២ ៦៩៦តោន ទៅកាន់ប្រទេសកូរ៉េ សិង្ហបុរី ថៃ វៀតណាម និងហុងកុង។ គ្រាប់ពោតចំនួន ៥៤ ៤៤៣តោន ទៅកាន់ប្រទេសកូរ៉េ ថៃ និងប្រទេសវៀតណាម។ គ្រាប់ស្វាយចន្ទីចំនួន ៤ ៤៥០តោន ទៅកាន់ប្រទេសវៀតណាម និងប្រទេសថៃ។ ម្រេចចំនួន ៤តោន ទៅកាន់ប្រទេសបែលហ្ស៊ិក ជប៉ុន កូរ៉េ និងប្រទេសអាមេរិក។ ម្ទេសស្រស់ចំនួន ១៥ ២៥៣តោន ទៅកាន់ប្រទេសថៃ។

## ២ ផ្នែកផលិតកម្មកៅស៊ូ

**២.១ ផ្ទៃដីកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១១៨ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៤៩៧ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦២១ហ.ត ស្មើនឹង២៨%។

**២.២ ផលិតកម្មកៅស៊ូ**

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៣២ ៨៤៣តោន កើនឡើងចំនួន ៣ ៦៤០តោន ស្មើនឹង១២% ធៀបខែកុម្ភៈ ឆ្នាំ២០២០។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ៣០ ៩០៩តោន កើនឡើងចំនួន ៣ ៤០២តោន ស្មើនឹង១២% ធៀបខែកុម្ភៈ ឆ្នាំ២០២០។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់មធ្យមគឺ១ ៥៥៧ដុល្លារ/តោន កើនឡើងចំនួន ១២៩ដុល្លារ/តោន ស្មើនឹង៩% ធៀបខែកុម្ភៈ ឆ្នាំ២០២០។
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែកុម្ភៈ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៥៧៥៛/គ.ក្រ ដល់ ៥ ៨០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ១៥០៛/គ.ក្រ ដល់ ២ ៧៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

**៣.១ ការងារព្រៃឈើ**

- បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១ និងទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ ចំនួន ៥ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 ចំនួន ៥ផ្ទាំង
- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ១២គ្រឿង និងយានយន្តចំនួន ២២គ្រឿង ជូនក្រុមហ៊ុន លឹម រ៉ូយ៉ាល់ និងក្រុមហ៊ុន ណេង ណា ក្នុងខេត្តមណ្ឌលគិរី
- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់ មានឈើហ៊ុបមូលចំនួន ២ ៤៨២ម៣ កូនឈើចំនួន ៤១ ២៤៤ដើម អុសចម្រុះចំនួន ១០ ៧៣០ស្ទែរ និងជ័រទឹកចំនួន ១០០តោន។

**៣.២ ការងារអភិរក្សសត្វព្រៃ**

- បានចុះប្រមូលលាមកសត្វដំរីព្រៃនៅក្នុងតំបន់ព្រៃឡង់ ខេត្តស្ទឹងត្រែងចំនួន ១៩សំណាក និងបញ្ជូនទៅរក្សាទុក និងវិភាគ DNA នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដើម្បីកំណត់ចំនួន និងចម្រុះភាពសេនេទិចក្រុមដំរីដែលកំពុងរស់នៅ និងបន្តពូជនៅក្នុងដែនជម្រកសត្វព្រៃនៃតំបន់ព្រៃឡង់
- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនវ៉ាន់នី បាយអូរីស៊ើច ខេមបូឌា ចំនួន ២ច្បាប់ មានសត្វស្វាក្ដាមចំនួន ១ ០៨០ក្បាល ដែលដឹកចេញពីខេត្តពោធិ៍សាត់ឆ្ពោះទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៨ច្បាប់ សម្រាប់ថែរក្សាសត្វត្រចៀកកាំ មានទីតាំងស្ថិតនៅខេត្តកោះកុង ពោធិ៍សាត់ តាកែវ កណ្តាល បន្ទាយមានជ័យ និងខេត្តសៀមរាប។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាម សរុបចំនួន ៧១ ៥៨៩ក្បាល ក្នុងនោះកូនកើតក្នុងខែមានចំនួន ៥ ៤០៩ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦៤២ក្បាល(បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៨២ក្បាល ព្យាបាលសត្វព្រៃ របួសឈឺចំនួន ៣២ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៨១ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០នាក់ បានចុះល្បាតនៅ តំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ៖ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) ដោយអង្កេតតាមដានប្រចាំឆ្នាំរកឃើញក្រពើភ្នំចំនួន ២ក្បាល លាមកក្រពើចំនួន ៧៤ដុំ និងដានជើង ចំនួន ១១កន្លែង

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង ១២ ០០០ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃទំហំ ២,២០ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងរដ្ឋបាលខេត្តឧត្តរមានជ័យចុះកំណត់ចំណុច និយាមកាបោះបង្គោលព្រំដីចំនួន ៩៥ចំណុច លើផ្ទៃដីទំហំ ៧ ៣២២ហ.ត នៅទីតាំងសម្រាប់វិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម និងដាំឈើដៃគូសហការរវាងក្រុមហ៊ុន សាន ហ៊ាង (កម្ពុជា) អាហារ័ណ នីហរ័ណឯ.ក ជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើសំរោងកូនក្រៀល ស្ថានីយពង្រចុងកាល់ និងស្ថានីយកូន-ក្រៀល

- បាននិងកំពុងថែទាំចម្ការឈើសរុប ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្ម ៤៤ហ.ត ចម្ការឈើដាំទំហំ ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ បានសម្អាតស្លឹកឈើ ស្មៅ នៅចន្លោះរងកូនឈើ

- បានបណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ៤៥ ៩៩៤ដើម ក្នុងនោះបណ្តុះកូនឈើដោយខណ្ឌរដ្ឋបាលព្រៃឈើ រាជធានី-ខេត្តចំនួន ៧ ២៩៤ដើម និងថ្នាលបណ្តុះកូនឈើចំនួន៦ ចំនួន ៣៨ ៧០០ដើម និងចែកចាយកូនឈើសម្រាប់ ដាំអាស្រ័យផលបានចំនួន ៥ ៩៦០ដើម ដោយខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៩៦០ដើម និងថ្នាលបណ្តុះកូន ឈើដែលបានទទួលថវិកាពីនាយកដ្ឋាន (ថវិការដ្ឋ) សរុបចំនួន ៥ ០០០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៦៣ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១ក្នុងខេត្តមណ្ឌលគិរី

- បានចុះពិនិត្យសំណើសុំពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូល តែមួយ) ចំនួន ៤ក្នុងរាជធានីភ្នំពេញ ខេត្តព្រៃវែង រតនគិរី និងខេត្តកំពង់ធំ

- បានចុះពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ ១កន្លែង

- ក្រុមហ៊ុនចំនួន ៦បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសចំនួន ៣៤១ម$^{៣}$ និង ជ័រទឹកចំនួន ១០៨តោន

- ក្រុមហ៊ុនចំនួន ២បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ២៦២ម$^{៣}$

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ១មានឫស្សីកែច្នៃចំនួន ២៥តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ១មានឈើកែច្នៃចំនួន ៦០០ម$^{៣}$។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ៦៧០ ៨៣១ ៨១៥រៀល និង ៥៥៤ ១៤០,៤៤ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៩ករណី។ រាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៦ ៧៣៥លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**
  ចូលរួមផ្សព្វផ្សាយ និងទប់ស្កាត់ជំងឺផ្តាសាយបក្សីនៅឃុំនរិទ្ធ ស្រុកឯកភ្នំ ខេត្តបាត់ដំបង។
- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១ ១០៤វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបានចំនួន ១០តោន សរុបរយៈពេល២ខែចំនួន ១ ៣១០តោន ស្មើនឹង១០,៩២% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ២៥ ២០០តោន សរុបរយៈពេល២ខែចំនួន ៤៤ ០០០តោន ស្មើនឹង១២,៧៥% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ៤ ០០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៥ ៨០០តោនសរុបរយៈពេល២ខែចំនួន ១១ ៩០០តោន ស្មើនឹង៨,២១% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ៩០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨ ៤៣០តោន សរុបរយៈពេល២ខែចំនួន ១៦ ០៨០តោន ស្មើនឹង១២,៣៧% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ កើនឡើងចំនួន ៨០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២០ ៨៨០តោន សរុបរយៈពេល២ខែចំនួន ៣៩ ៨៤០តោន ស្មើនឹង ៨,២៨% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ កើនឡើងចំនួន ៦ ៦៤០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១៣ ៦០០ក្បាល សរុបរយៈពេល២ខែចំនួន ២៣ ០០០ក្បាល ស្មើនឹង៦,៩៧% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ២ ៧០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២៣ ០៥០ ០០០កូន សរុបរយៈពេល២ខែចំនួន ៣៨ ១០០ ០០០កូន ស្មើនឹង១៤,១១% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១ ៥០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៥ ៣១០តោន សរុបរយៈពេល២ខែចំនួន ១០ ៩១០តោន ស្មើនឹង ១៣,៦៤% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ២ ០០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៤០០តោន សរុបរយៈពេល២ខែចំនួន ២ ៣០០តោន ស្មើនឹង១៩,១៧% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ កើនឡើងចំនួន ៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៨ ៥០០ ០០០លីត្រ សរុបរយៈពេល២ខែចំនួន ១១ ៥០០ ០០០លីត្រ ស្មើនឹង ២០,៩១% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ៥០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៥៣ករណី ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ៤៤ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៥២ករណី និងសមុទ្រចំនួន ១ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៤០៧តោន សរុបរយៈពេល២ខែចំនួន ៦៧០តោន ស្មើនឹង៤,៤៧% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ២៤៨តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ៨១តោន សរុបរយៈពេល២ខែចំនួន ១៧០តោន ស្មើនឹង៣,៤០% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀប ខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ២៦តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាជលផលបានចំនួន ៣១ ៥៣៣ ៦២៥រៀល សរុបរយៈពេល២ខែចំនួន ៣១ ៥៣៣ ៦២៥រៀល ស្មើនឹង ៨,៧៩% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២០ ថយចុះចំនួន ២៨ ៣៦២ ៥៥៥រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផលិតផលជលផលនាំចេញ នាំចូល និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តតាកែវ កណ្តាល ព្រៃវែង កំពត និងខេត្តត្បូងឃ្មុំ

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងបានណែនាំឱ្យកែលម្អកន្លងមក

- ពុំមានការទទួលពាក្យបណ្តឹងតាមរយៈគេហទំព័រលើប្រព័ន្ធអ៊ិនធើណេត (www.gi.maff.gov.kh)

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១៣៧ករណី

- ការចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ១២លើក

- បានចេញលិខិតកែលម្អចំណុចខ្វះខាតសរុបចំនួន ២លិខិត។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧៣៨ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៩៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៩៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៤៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៧៥២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥២ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៤ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨៣៦នាក់ (ស្រី១៩១៧នាក់ ស្មើនឹង២៤,២៨%) រួមមាន៖
  - + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៥នាក់ (ស្រី៨២៣នាក់ ស្មើនឹង២៨,២៣%)
  - + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩២១នាក់ (ស្រី៥៩៤នាក់ ស្មើនឹង២០,៣៣%)
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៩នាក់
- បានរៀបចំប្រកាសស្តីពីការផ្ទេរមន្ត្រីរាជការទៅក្រៅក្រសួងចំនួន ១នាក់
- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌដោយសុំលាឈប់ចំនួន ៤នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន ៨នាក់ (ស្រី៦នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ៥នាក់ និងច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ៣នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ២នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៨នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២០០នាក់ (ស្រី ៤១នាក់) ក្នុងនោះ៖
  - + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១៩៨នាក់ (ស្រី៤០នាក់)
  - + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ២នាក់ (ស្រី១នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានឆ្លើយតបទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើករណីសុំទិន្នន័យសម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
- បានចុះពិនិត្យ ផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង
- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក
- បានធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១
- បានពិនិត្យតាមដានល្បឿនការងារបង្កបង្កើនផលស្រូវប្រាំងឆ្នាំ២០២០-២០២១
- បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី-ខេត្ត
- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍នៅរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានីខេត្តចំនួន២៥ និងបានបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលបានទឹកប្រាក់សរុបចំនួន ៥ ០៩១ ៤១០ ១០៦លានរៀល
- បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS សរុបទឹកប្រាក់ចំនួន ៤ ៩០៥ ៧៩៩ ៧៧៩លានរៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៨ ៦៥៨ ៩៤០ ៦៨០លានរៀល
- បានរៀបចំសំណើសុំថវិកាចំនួន២ ១១៩ ៣២៨ ០០០រៀលសម្រាប់បំពេញចូលគណនីកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ(CAPFISH-Capture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប
- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ១២ក្រុមហ៊ុន
- បានចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ ត្បូងឃ្មុំ ក្រចេះ កំពត និងកំពង់ស្ពឺ ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ (ឆ្នាំគោល) និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល

- បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០២១-២០២៣ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការវជ្ជ-ទេយ្យបុរេប្រទានឆ្នាំ២០២១

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំចំនួន ១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី

- បានសម្របសម្រួលរៀបចំកិច្ចប្រជុំចំនួន ៣លើក

- បានសម្របសម្រួលការចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១គម្រោងគិតជាទឹកប្រាក់ចំនួន ៤ ៣៥០ ០០០ដុល្លារអាមេរិក

- បាននិងកំពុងសម្របសម្រួលការស្នើសុំចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងរបស់អង្គការ Swisscontact និងអង្គការអភិរក្សនិងការពារសត្វព្រៃ

- បានសម្របសម្រួលរៀបចំការចុះហត្ថលេខាវាងអង្គការ FAO ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពី Climate Adaptationand Resilience in Cambodia Coastal Fishery Dependent Communities។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៤ក្រុមហ៊ុន សរុបចំនួន ២១៤មុខ

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៥ក្រុមហ៊ុន

- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ២៩សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

បានពិនិត្យ និងផ្តល់មតិចំនួន ២ករណី។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១១ក្រុមហ៊ុន

- អនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ៥ក្រុមហ៊ុន

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ៤ខេត្ត គឺខេត្តបន្ទាយ-មានជ័យ បាត់ដំបង ព្រះសីហនុ និងខេត្តកោះកុង។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានដាក់ឲ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ

- បានបង្កើត Sub Domain (dal.maff.gov.kh) របស់នាយកដ្ឋាននីតិកម្មកសិកម្មសម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធ QR Code នៃព័ត៌មានផលិតផលថ្នាំកសិកម្មដែលបានចុះបញ្ជី

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានសម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្តាលលើគេហទំព័រផុសចំនួន ១២ព័ត៌មាន

- តំឡើងប្រព័ន្ធ Firewall សម្រាប់ម៉ាស៊ីនមេដើម្បីការពារការលុកចូលពីខាងក្រៅ (Hacker)

- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១៦ក្បាល/ច្បាប់។

### ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹម និងភ្ញាស់ពូជមាន់ខ្មៅ មាន់ស្រែ ត្រីអណ្តែង ត្រីឆ្តោ ខ្យង និងកង្កែប ដំណាំបន្លែខាត់ណាដើម ខាត់ណាផ្កាក្នុងផ្ទះសំណាញ់ ផលិតកម្មសត្វការចិញ្ចឹមទានៅខេត្តមណ្ឌលគិរី ក្រចេះ កណ្តាល និងខេត្តតាកែវ

- បានចុះទៅថត Video បទយកការណ៍ចំនួន ១ប្រធានបទ
- បានធ្វើការផលិត Video និងចាក់ផ្សាយឡើងវិញចំនួន ១ប្រធានបទ
- បានផលិត Video នាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ
- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ
- បានជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ១៨សំណួរចម្លើយ។

### ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាចាប់ផ្តើមអនុវត្ត និងពិធីចុះអនុស្សរណៈយោគយល់គ្នាស្តីពីគម្រោងបន្លែផ្លែឈើកម្ពុជា

- បានចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងផ្តល់ធាតុចូលលើក្របខ័ណ្ឌជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា

- បានចូលរួមប្រជុំលើកទី១របស់ក្រុមការងារអន្តរក្រសួង តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីរបាយការណ៍សិក្សាស្វែងយល់ពីវឌ្ឍនភាព និងឧបសគ្គក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣

- បានបន្តបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិករោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី ជ័យសំបូរ នៅខេត្តកំពង់ធំអំពីប្រព័ន្ធ HACCP ការប្រើប្រាស់ឧបករណ៍ សម្ភារ និងគ្រឿងម៉ាស៊ីន

- បានចូលរួមដំណើរការជាមួយអ្នកជំនាញការ JICA ចុះពិនិត្យ និងសិក្សាបញ្ហាពាក់ព័ន្ធនឹងខ្សែច្រវាក់ផលិតកម្មស្វាយចន្ទីរបស់សហគមន៍កសិកម្មដែលស្នើសុំគម្រោង KUSANONE នៃរដ្ឋាភិបាលជប៉ុននៅខេត្តកំពង់ធំ

- បានចូលរួមរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងគុណភាព និងសុវត្ថិភាពក្រោយប្រមូលផលនេសាទសមុទ្រនៅខេត្តព្រះសីហនុជាមួយជំនាញការជប៉ុនលើខ្សែច្រវាក់តម្លៃប្រចាំនៅនាយកដ្ឋានកសិ-ឧស្សាហកម្ម។

### ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

#### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានទទួល H.E. Pablo Kang ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ព្រមទាំងមន្ត្រីកាវ៉ាក់ (CAVAC) មកធ្វើទស្សនកិច្ចស្រែពិសោធន៍ និងScreening House ក្រោមកិច្ចសហការនិងគាំទ្រវាងវិទ្យាស្ថាន និងកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC)

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកម្មវិធីសិក្សាអំពីការប្រើប្រាស់ថាមពលកកើតឡើងវិញ (RET)

- បានចូលរួមប្រជុំពិនិត្យ និងពិភាក្សាលើឯកសារគោលការណ៍ណែនាំស្តីពីការធ្វើពិពិធកម្មដំណាំជាយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្មនៅកម្ពុជាលើមធ្យោបាយឆ្ពោះទៅមុខ

- បានចុះត្រួតពិនិត្យ និងអនុវត្តការងារពិសោធន៍នៅស្ថានីយកោះកេរ្តិ៍នៅខេត្តព្រះវិហារ
- បានចុះប្រមូលផល និងស្រង់ទិន្នន័យពិសោធន៍នៅខេត្តព្រះវិហារ
- បានចុះពិភាក្សាការងារ និងត្រួតពិនិត្យស្រែពិសោធន៍នៅខេត្តតាកែវ និងខេត្តព្រៃវែង
- បានចុះសិក្សា និងវាយតម្លៃដីកសិកម្មនៅខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ
- បានចុះពិនិត្យជុំវិញការស្រាវជ្រាវបច្ចេកទេសដាំដុះថ្មីៗនៅស្ថានីយស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍នៅខេត្តព្រះវិហារ។

#### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រ

ជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប៉ាន់ប្រមាណប្រព័ន្ធនវានុវត្តន៍កសិកម្មក្នុងក្របខ័ណ្ឌគម្រោង ការអភិវឌ្ឍសមត្ថភាព និងស្ថាប័នក្នុងប្រព័ន្ធនវានុវត្តន៍កសិកម្មដែលទទួលបានការឧបត្ថម្ភថវិកាពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FAO)

- បានចុះធ្វើការសិក្សា និងវាយតម្លៃសក្តានុពលនៃប្រព័ន្ធជីវឧស្ម័ន ធ្វើបទបង្ហាញអំពីរបាយការណ៍វាយតម្លៃសង្ខេបអំពីគម្រោងសាងសង់ប្រព័ន្ធជីវឧស្ម័ន និងពិភាក្សាអំពីនីតិវិធីការគាំទ្រហិរញ្ញប្បទានក្នុងដំណាក់កាលដំបូងជូនម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូកនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះសីហនុ និងសហការដឹកនាំចុះរៀបចំថតវីដេអូផ្សព្វផ្សាយមជ្ឈមណ្ឌលជាមួយកសិដ្ឋាន M's pig និងចុះពិនិត្យដំណើរការប្រព័ន្ធចម្រោះឧស្ម័ននៅក្នុងកសិដ្ឋាននោះតែម្តង។

## ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយ និងស្បៀង និងភាសាអង់គ្លេស

- បានរៀបចំកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ឱ្យចប់ជាស្ថាពរដើម្បីផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសុំការគាំទ្រ និងបន្ទាប់ទៀតគឺត្រូវបញ្ជូលទៅសុំការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធន៍ចិញ្ចឹមគោទឹកដោះ ការពិសោធន៍ចិញ្ចឹមបង្គា ការពិសោធន៍បង្កាត់ពូជមាន់ ការសិក្សាពិសោធន៍ថ្នាំបណ្តេញសត្វល្អិត ការពិសោធន៍ចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់គេសរកូល ការពិសោធន៍ដំណាំព្រីង ការសិក្សាពិសោធន៍ផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធន៍ចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធន៍ចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ

- បានចូលរួមសិក្ខាសាលាស្តីពីគម្រោងបន្លែ ផ្លែឈើកម្ពុជា ដំណាក់កាលទី៣ សិក្ខាសាលាផ្សព្វផ្សាយផែនការសកម្មភាពស្តីពីភាពស៊ាំឱសថប្រឆាំងនឹងមេរោគនៅកម្ពុជាឆ្នាំ២០១៩-២០២០ និងសិក្ខាសាលាយុទ្ធសាស្ត្រឆ្លើយតបផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។

## ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៥៨៨នាក់ (ស្រី២៦៨នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូ និង៥៦០កូន

- បានធ្វើការពិសោធន៍លើការចិញ្ចឹមសាកល្បងពូជកន្ទាយក្នុងស្រុកចំនួន ៤៥០ក្បាល

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច

- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរីនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

## ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូន កូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍ក្លូនចំនួន ១២ចម្ការពិសោធន៍

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នាដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- ត្រួតពិនិត្យការប្រមូលផលទឹកជ័រនៅចម្ការពិសោធន៍

- អនុវត្តការបំបៅកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២០-២០២១

- ត្រួតពិនិត្យការបោសសម្អាតសន្លឹកកៅស៊ូនៅក្នុងឡូតិ៍ និងការពារភ្លើងឆេះ

- ត្រួតពិនិត្យការងារកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ

- ត្រួតពិនិត្យសម្ភារ និងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦៣០ ៨៣ហ.ត ស្មើនឹង១៣៧,៣៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត ដោយការប្រមូលផលស្រូវប្រាំងបានចំនួន ២៤៧ ០៨៩ហ.ត ទទួលបរិមាណផលសរុបចំនួន ១ ០៩០ ៣៣៤តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៤១៣តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំ-កសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួត-ពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០២១

- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុនអាហ្វ្រិក/ត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គុរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បាននិងកំពុងរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់

ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃ សុក្រ ៧កើត ខែ ភទ្របទ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**